ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

ក្នុងគោលបំណងធានាការអនុវត្តយ៉ាងត្រឹមត្រូវ និងប្រសិទ្ធភាពនូវច្បាប់នានា និងដើម្បីពង្រឹងនីតិរដ្ឋ និងការគោរពអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ហើយបន្ទាប់ពីមានការពិចារណានិងការពិភាក្សាគ្នាយ៉ាងហ្មត់ចត់ក្នុងកិច្ចប្រជុំជាបន្តបន្ទាប់រួចមក អាជ្ញាធរមានសមត្ថកិច្ចរបស់កម្ពុជា បានឈានដល់ការសម្រេចបញ្ឈប់នូវសកម្មភាពរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) និងបណ្តេញបុគ្គលិកបរទេសរបស់វិទ្យាស្ថាននេះ ចេញពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល៧ថ្ងៃ បន្ទាប់ពីការជូនដំណឹងជាផ្លូវការអំពីសេចក្តីសម្រេចនេះ។

ដើម្បីបំភ្លឺចំពោះការប្រកាន់យកសេចក្តីសម្រេចនេះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សូមជម្រាបជូនសាធារណមតិជាតិនិងអន្តរជាតិ អំពីមូលដ្ឋានច្បាប់នៃសេចក្តីសម្រេចនេះ ពិសេសគឺច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសារពើពន្ធ ដូចខាងក្រោម៖

- ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ និងប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះករុណាព្រះមហាក្សត្រ នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៥។
- ចាប់តាំងពីច្បាប់នេះបានចូលជាធរមាន នៅខែសីហា ឆ្នាំ២០១៥ អង្គការNDI បានធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយមិនបានចុះបញ្ជីជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រហូតដល់អង្គការនេះបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៦។ អំឡុងពេលរង់ចាំការសម្រេចរបស់ក្រសួងលើពាក្យស្នើសុំនេះ អង្គការNDI នៅតែបន្តធ្វើសកម្មភាពរបស់ខ្លួនដោយគ្មានគិតគូអំពីការគោរពច្បាប់សោះឡើយ។
- មាត្រា៣៤នៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ចែងថា៖ "អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ វិធានការបន្ថែមទាក់ទងនឹងការ



អាសយដ្ឋាន៖ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

បណ្តេញចេញស្របតាមច្បាប់ស្តីពីអន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណា ដែលបម្រើការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលប្រព្រឹត្តល្មើស ខាងលើ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត"។

- មាត្រា១០១ នៃច្បាប់ស្តីពីសារពើពន្ធ ចែងថា៖ "បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង១៥ថ្ងៃក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច"។
- មាត្រា១២៨ និង ១២៩ នៃច្បាប់ដដែលនេះ ចែងថា៖ "ក្នុងករណីដែលបុគ្គល មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ" និងថា៖ "...បុគ្គលណាដែលធ្វើការរាំងស្ទះដល់ការគ្រប់គ្រងប្រព័ន្ធសារពើពន្ធដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះ ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។"
- បន្ថែមលើនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពន្យល់យ៉ាងលម្អិតអំពីច្បាប់នេះ ហើយនិងវិធានការរបស់អគ្គនាយកដ្ឋានសម្រាប់ការអនុវត្តច្បាប់នេះ នៅក្នុងសេចក្តីបំភ្លឺរបស់ខ្លួន ចេញផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧។
- អង្គការ NDI រហូតមកដល់បច្ចុប្បន្ន មិនបានអនុវត្តតាមច្បាប់ដែលបានលើកឡើងខាងលើនេះឡើយ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមគូសបញ្ជាក់ថា ក្នុងពេលដែលសេចក្តីសម្រេចនេះ កំពុងត្រូវបានអនុវត្តចំពោះអង្គការ NDI និងបុគ្គលិកបរទេសរបស់អង្គការនេះ អាជ្ញាធរមានសមត្ថកិច្ចក៏បានត្រៀមលក្ខណៈរួចជាស្រេចក្នុងការចាត់វិធានការបែបនេះផងដែរ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលមិនគោរពតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ហើយនិងច្បាប់ផ្សេងៗទៀតរបស់ព្រះរាជាណាចក្រកម្ពុជា។

ភ្នំពេញ, ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៧